# តើអ្នកមានជំងឺមហារីកសុដន់ឬមហារីកមាត់ស្បូនមែនដែរឬទេ? ព្រួយបារម្ភអំពីការបង់ថ្លៃព្យាបាលមែនទេ?

អ្នកអាចនឹងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទទួលបានកម្មវិធី Medi-Cal ពិសេសសម្រាប់អ្នកដែលមានជំងឺមហារីកសុដន់ មហារីកមាត់ស្បូន ឬទាំងពីរ។ ប្រសិនបើអ្នកមានសិទ្ធិទទួលបាន នោះកម្មវិធីនឹងរ៉ាប់រងលើការព្យាបាលរបស់អ្នក។ កម្មវិធីនេះហៅថា កម្មវិធីព្យាបាលជំងឺមហារីកសុដន់ និងមហារីកមាត់ស្បូន ឬ "BCCTP។"

មនុស្សគ្រប់វ័យ គ្រប់ស្ថានភាពអន្តោប្រវេសន៍ និងគ្រប់អត្តសញ្ញាណយេនឌ័រ អាចនឹងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទទួលបាន BCCTP។ អ្នកអាចនឹងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទទួលបាន ទោះបីជាអ្នកមិនអាចទទួលបាន Medi-Cal កាលពីមុន ឬ Medi-Cal របស់អ្នកបានបញ្ចប់រួចហើយក៏ដោយ។ អ្នកក៏អាចនឹងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ផងដែរ ប្រសិនបើអ្នកមានការធានារ៉ាប់រងសុខភាពផ្សេងទៀត។

អ្នកត្រូវតែមានរោគវិនិច្ឆ័យដំណាក់កាលមុនកើតជំងឺមហារីកមាត់ស្បូន ជំងឺមហារីកមាត់ស្បូន ឬមហារីកសុដន់ និងត្រូវការការព្យាបាលឬថែទាំតាមដានជាចាំបាច់។ អ្នកក៏ត្រូវតែរស់នៅក្នុងរដ្ឋ California និងបំពេញតាមលក្ខខណ្ឌតម្រូវស្តីពីចំណូលជាក់លាក់ផងដែរ។

## ▶ មានវិធីចំនួន 2 ដើម្បីដាក់ពាក្យស្នើសុំកម្មវិធីព្យាបាលជំងឺមហារីកសុដន់ និងមហារីកមាត់ស្បូន (BCCTP)។

1. **ពិភាក្សាជាមួយវេជ្ជបណ្ឌិតរបស់អ្នក។** សួរថាតើពួកគេជាផ្នែកនៃកម្មវិធី *Every Woman Counts* ឬ *Family PACT* ដែរឬទេ។ ប្រសិនបើពួកគេជាផ្នែកមួយនៃកម្មវិធីទាំងនេះ នោះពួកគេអាចដាក់ពាក្យសុំឲ្យអ្នកបាន។ វេជ្ជបណ្ឌិតជាច្រើននៅទូទាំងរដ្ឋ California គឺជាផ្នែកមួយនៃកម្មវិធីទាំងនេះ។

   ប្រសិនបើអ្នកចង់បានជំនួយក្នុងការស្វែងរកវេជ្ជបណ្ឌិតមួយរូបដែលចូលរួម នោះអ្នកអាច៖

   ទាក់ទងទៅកាន់កម្មវិធី *Every Woman Counts* ដើម្បីស្វែងរកវេជ្ជបណ្ឌិតជំងឺមហារីកសុដន់

ឬមហារីកមាត់ស្បូនដែលនៅជិតលោកអ្នក។

- ទូរសព្ទទៅកាន់លេខ៖ (800) 511-2300
- ចូលទៅកាន់៖ www.dhcs.ca.gov/services/cancer/EWC/Pages/ewc-clinic-locator.aspx

ទាក់ទងទៅកាន់កម្មវិធី *Family PACT* ដើម្បីស្វែងរកវេជ្ជបណ្ឌិតជំងឺមហារីកមាត់ស្បូនដែលនៅជិតលោកអ្នក។

- ទូរសព្ទទៅកាន់លេខ៖ (916) 650-0414

**2. ពិភាក្សាជាមួយបុគ្គលិកផ្នែកសិទ្ធិទទួលបានប្រចាំខោនធី។**

ប្រាប់ពួកគេថាអ្នកមានជំងឺមហារីកសុដន់ ឬមហារីកមាត់ស្បូន និងចង់ចុះឈ្មោះចូលរួមកម្មវិធី BCCTP។

បុគ្គលិកផ្នែកសិទ្ធិទទួលបានប្រចាំខោនធី នឹងបញ្ជូនព័ត៌មានរបស់អ្នកទៅកាន់អ្នកជំនាញឯកទេសផ្នែកសិទ្ធិទទួលបាននៃកម្មវិធី BCCTP។ អ្នកជំនាញឯកទេសផ្នែកសិទ្ធិទទួលបាននៃកម្មវិធី BCCTP នឹងឲ្យអ្នកបានដឹងតាមរយៈសំបុត្រប្រៃសណីយ៍ថាតើអ្នកត្រូវបានអនុញ្ញាតសម្រាប់កម្មវិធី BCCTP ដែរឬអត់។

បុគ្គលិកផ្នែកសិទ្ធិទទួលបានប្រចាំខោនធី ក៏នឹងត្រួតពិនិត្យមើលថាតើអ្នកមានសិទ្ធិទទួលបាន Medi-Cal ដែរឬអត់។ ពួកគេនឹងឲ្យអ្នកបានដឹង តាមរយៈសំបុត្រប្រៃសណីយ៍ថាតើអ្នកត្រូវបានអនុញ្ញាតសម្រាប់ Medi-Cal ដែរឬអត់។

- ស្វែងយល់បន្ថែមនៅលើ www.dhcs.ca.gov/services/medi-cal/Pages/BCCTP.aspx